សង្ខេបសម្រាប់
គោលនយោបាយ

CDRI គឺជាវិទ្យាស្ថានកម្ពុជាឯករាជ្យឈានមុខគេ
សម្រាប់ការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍

ឆ្នាំ ២០១១ លេខ ០៣

# តម្លៃនៃការប្រើប្រាស់ទឹក និងការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ នៅក្នុងផលិតកម្មស្រូវនៅកម្ពុជា[១]

*ដោយ Chris WOKKER[២] Paulo SANTOS[២]*

*រស់ បានសុខ[៣] និង Kate GRIFFITHS[៤]*

## ខ្លឹមសារសំខាន់ៗ

- រាជរដ្ឋាភិបាលកម្ពុជា បានផ្តល់អាទិភាពដល់ការរៀបចំស្តារ និងកសាងប្រព័ន្ធស្រោចស្រព ដើម្បីបង្កើនផលិតកម្មកសិកម្ម ជាពិសេសដំណាំស្រូវ ហើយធានាបាននូវសុវត្ថិភាពស្បៀង និងការលូតលាស់សេដ្ឋកិច្ចជាតិ ។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលរំពឹងថាប្រជាកសិករ ពិតជាចូលរួមកុះករក្នុងការប្រើប្រាស់ គ្រប់គ្រង និងថែរក្សាប្រព័ន្ធធារាសាស្ត្រទាំងនោះប្រកបដោយនិរន្តរភាព ជាជាងនៅតែពឹងផ្អែកទាំងស្រុងទៅលើរដ្ឋាភិបាល ។
- ដោយយោងទៅលើសារាចរស្តីពី ការអនុវត្តគោលនយោបាយនិរន្តរភាពនៃប្រព័ន្ធធារាសាស្ត្រ រដ្ឋាភិបាលបានកំណត់នូវ ការប្រមូលយកថ្លៃប្រើប្រាស់ទឹកពីកសិករ ដើម្បីធ្វើជាមធ្យោបាយសម្រាប់ការគ្រប់គ្រងថែទាំប្រព័ន្ធធារាសាស្ត្រ ។ ការប្រមូលយកថ្លៃប្រើប្រាស់ទឹកនេះ គេបានរៀបចំឲ្យដំណើការស្របតាមគោលការណ៍វិមជ្ឈការនៅថ្នាក់មូលដ្ឋាន តាមរយៈសហគមន៍កសិករប្រើប្រាស់ទឹក ( សកបទ ) ។
- របកគំហើញពីការសិក្សាបានបង្ហាញថា តម្លៃប៉ាន់ស្មាននៃការប្រើប្រាស់ទឹកសំរាប់ផលិតកម្មស្រូវ ជាពិសេសស្រូវវស្សានៅមានកម្រិតទាប ដូច្នេះ នៅក្នុងគោលនយោបាយជាតិ បើសិនមានការកំណត់យកថ្លៃកម្រិតខ្ពស់បន្តិចលើការប្រើប្រាស់ទឹក គឺប្រហែលមិនអាចយកទៅអនុវត្តបានល្អទេ ។
- ផលិតកម្មស្រូវប្រាំង ទទួលបានទិន្នផលខ្ពស់ច្រើនគួរសម បើប្រៀបធៀបទៅនឹងទិន្នផលស្រូវវស្សា ប៉ុន្តែវិសាលភាពនៃការប្រើប្រាស់ទឹក ពីប្រព័ន្ធធារាសាស្ត្រនៅមានកម្រិតនៅឡើយ ។ បញ្ហាទាំងអស់នេះ ត្រូវមានការសិក្សាបន្ថែមទៀត ដើម្បីស្វែងយល់ច្បាស់ពីមូលហេតុរបស់វា ។

---

១ អត្ថបទសង្ខេបសម្រាប់គោលនយោបាយនេះ ដកស្រង់ចេញពីឯកសារសិក្សាស្រាវជ្រាវរបស់អ្នកនិពន្ធ Chris Wokker, Paulo Santos, រស់ បានសុខ និង Kate Griffiths ក្នុងឆ្នាំ២០១០ ដែលមានចំណងជើងថា ផលិតកម្មស្រូវនៅកម្ពុជាតាមការប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រ។ ឯកសារនេះបង្ហាញពីលទ្ធផលការសិក្សាក្នុងសមាសភាគសេដ្ឋកិច្ចនៃកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវគ្រប់គ្រងធនធានទឹក ដែលជាកម្មវិធីសិក្សាស្រាវជ្រាវរយៈពេល ៥ឆ្នាំ ទទួលបានហិរញ្ញប្បទានពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិអូស្ត្រាលី (AusAID) ដើម្បីជួយកែលម្អការប្រើប្រាស់និងអភិបាលកិច្ចធនធានទឹកសំដៅលើកកំពស់ផលិតភាពកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាពនៅកម្ពុជា។

២ មកពី មហាវិទ្យាល័យកសិកម្ម ស្បៀងអាហារ និងធនធានធម្មជាតិ នៃសាកលវិទ្យាល័យ ស៊ីដនី។

៣ មកពី កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) ។

៤ មកពី មជ្ឈមណ្ឌលអូស្ត្រាលីសិក្សាធនធានទន្លេមេគង្គ នៃសាលាភូគព្ភសាស្ត្រ នៃសាកលវិទ្យាល័យស៊ីដនី។

## បញ្ហាចោទ

សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកមួយភាគធំលើ វិស័យកសិកម្ម ដែលបានចូលរួមចំណែក ៣៣% នៃ ផសស របស់ជាតិ និងផ្តល់ការងារដល់ប្រជាពលរដ្ឋលើសពី ៦៧% នៅក្នុងប្រទេសកម្ពុជា ។ ដោយឡែក ផលិតកម្មស្រូវដើរតួនាទីសំខាន់ណាស់ក្នុងវិស័យកសិកម្ម ហើយប្រជាកសិករភាគច្រើនមិនត្រឹមតែពឹងផ្អែកដោយផ្ទាល់ ឬដោយប្រយោលទៅលើជោគជ័យនៃការប្រមូលផលស្រូវ ក្នុងឆ្នាំនីមួយៗប៉ុណ្ណោះទេ ប៉ុន្តែស្រូវអង្ករក៏ជាស្បៀងអាហារមូលដ្ឋាន និងជាកត្តាដ៏សំខាន់ក្នុងកិច្ចប្រឹងប្រែង បង្កើនសន្តិសុខស្បៀងរបស់ប្រទេសជាតិផងដែរ ។

ទោះបីជាផលិតកម្មស្រូវសំខាន់ជាខ្លាំងដូច្នេះក្តី ក៏ការដាំដុះស្រូវនៅកម្ពុជានៅតែមានលក្ខណៈបុរាណ ដោយពឹងផ្អែកជាសំខាន់ទៅលើទឹកភ្លៀង ជាជាងលើប្រព័ន្ធធារាសាស្ត្រ ។ គេអាចនិយាយបានថា របបទឹកភ្លៀងជាកត្តាកំណត់ភាពជោគជ័យ និងទំហំនៃការប្រមូលផល ហើយជាទូទៅ កសិករតែងពឹងផ្អែកទៅលើការធ្វើស្រែតែម្តងគត់ក្នុងមួយឆ្នាំ ។ ក្នុងរដូវប្រាំង នៅពេលខ្វះខាតទឹក ការស្វះស្វែងរកទឹកជួបការលំបាក ហើយត្រូវចំណាយទាំងពេលវេលា និងប្រាក់កាស ។ ដោយបានទទួលស្គាល់ពីសារៈសំខាន់នៃការគ្រប់គ្រងទឹក ក្នុងការបង្កើនផលិតកម្មស្រូវ ទាំងរដ្ឋាភិបាលកម្ពុជា និងអ្នកផ្តល់ជំនួយនានា បានប្រឹងប្រែងច្រើនណាស់ក្នុងការជួសជុល ស្តារ និងកសាងប្រព័ន្ធធារាសាស្ត្រតូចធំ និងបន្តពង្រីកផ្ទៃដីស្រោចស្រពនៅទូទាំងប្រទេស ។ គេរំពឹងថា ប្រព័ន្ធធារាសាស្ត្រទាំងនោះ នឹងធ្វើឲ្យកសិករអាចកាត់បន្ថយការពឹងផ្អែកទៅលើទឹកភ្លៀង ហើយអាចដាំដុះបានកាន់តែច្រើន ទទួលផលបានកាន់តែទៀងទាត់ មានប្រាក់ចំណូលកាន់តែប្រសើរ និងមានកម្រិតជីវភាពកាន់តែខ្ពស់ ។ ឯកសារផែនការរបស់រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ២០០៩) បានសង្កត់ធ្ងន់ទៅលើសារៈសំខាន់នៃការគ្រប់គ្រងទឹក ជាពិសេស "ផែនការស្តារ និងលើកស្ទួយសក្តានុពលប្រព័ន្ធធារាសាស្ត្រ" ដើម្បីបង្កើនទិន្នផលកសិកម្ម ។

ទោះបីជា ប្រព័ន្ធស្រោចស្រពមានអាទិភាពខ្ពស់នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់កម្ពុជាក៏ដោយ ក៏នៅមិនទាន់មានការសិក្សាវិភាគពីបរិមាណទឹកនៅឡើយទេ ថាតើត្រូវធ្វើការគ្រប់គ្រងទឹកក្នុងស្រែបែបណា ពិសេសតម្លៃទឹកនៅក្នុងស្រែ ។ ព័ត៌មានទាំងនេះសំខាន់ខ្លាំងណាស់សម្រាប់ការស្វែងយល់ពី ឥទ្ធិពល និងផលប៉ះពាល់នានានៃគោលនយោបាយគ្រប់គ្រងធនធានទឹក ក្នុងនេះមានទាំងការកំណត់ឡើងវិញនូវការបែងចែកទឹក និងតម្លៃទឹកផងដែរ ។ ករណីសិក្សាជាបន្តបន្ទាប់ បានបង្ហាញនូវបកគំហើញសំខាន់ៗជាច្រើន តាមរយៈការសិក្សាផ្ទាល់ជាមួយគ្រួសារកសិករក្នុងខេត្តចំនួនបី នៅជុំវិញតំបន់ផ្ទៃរងទឹកភ្លៀងបឹងទន្លេសាប ដើម្បីធ្វើការប៉ាន់ស្មានអំពីតម្លៃទឹកចំពោះកសិករនៅក្នុងការបង្កើនផលិតកម្ម ។

## ករណីសិក្សា

ការចុះសិក្សាអង្កេតដល់កន្លែង បានធ្វើឡើងក្នុងខេត្តចំនួនបី គឺខេត្តកំពង់ឆ្នាំង កំពង់ធំ និងពោធិ៍សាត់ និងគ្របដណ្តប់ទៅលើប្រព័ន្ធធារាសាស្ត្រចំនួន ១០កន្លែង ។ ប្រព័ន្ធធារាសាស្ត្រនីមួយៗ ស្ថិតក្នុងតំបន់ផ្ទៃរងទឹកភ្លៀងបឹងទន្លេសាប និងតំណាងឲ្យលក្ខណៈផ្សេងៗគ្នានៃតំបន់ប្រព័ន្ធអេកូឡូស៊ីនៃដំណាំកសិកម្ម ។ អង្កេតបានធ្វើឡើងតាមការជជែកពិភាក្សា និងសម្ភាសជាមួយគ្រួសារនានាដែលស្ថិតនៅក្នុងប្រព័ន្ធធារាសាស្ត្រគោលដៅ ។

នៅក្នុងប្រព័ន្ធធារាសាស្ត្រនីមួយៗ គេបានជ្រើសយក ៣០គ្រួសារ មកធ្វើជាសំណាកសម្រាប់សម្ភាស ដោយគ្រួសារទាំងនោះមានលក្ខណៈចម្រុះគ្នា ទាក់ទិននឹងស្ថានភាពគ្រួសារ លក្ខណៈដីស្រែ ការប្រើប្រាស់ទឹកនៃប្រព័ន្ធធារាសាស្ត្រនីមួយៗ ។ល។ ការជ្រើសសំណាកបានធ្វើឡើងតាមការពិភាក្សា និងការជួយសម្របសម្រួលពីមនុស្សសំខាន់ៗ ដែលរស់នៅក្នុងតំបន់នៃប្រព័ន្ធធារាសាស្ត្រនីមួយៗ (ដូចជា មេភូមិ ឬប្រធាន សកបទ ឬសមាជិកក្រុមប្រឹក្សាឃុំ) ។ ការជួបសម្ភាសន៍ជាមួយគ្រួសារនានា ចាប់ធ្វើឡើងនៅពាក់កណ្តាលឆ្នាំ២០០៨ និងបន្តធ្វើទៀតនៅចុងរដូវវស្សា និងចុងរដូវប្រាំង រហូតដល់ពាក់កណ្តាលឆ្នាំ២០១០ ។ ទិន្នន័យប្រមូលបានរួមមាន ព័ត៌មានស្តីពីសមាសភាពតាមគ្រួសារ លក្ខណៈសំគាល់នៃមេគ្រួសារ (ដូចជា ភេទ អាយុ ការសិក្សាអប់រំ) លក្ខណៈដីស្រែ ទ្រព្យសម្បត្តិផ្សេងៗ ព្រមទាំងចំណូលពីការធ្វើស្រែ និងចំណូលពីប្រភពឯទៀតៗ ក៏ដូចជាការប៉ះពាល់ផ្សេងៗទៅលើផលិតកម្ម (ឧទាហរណ៍ ភាពរាំងស្ងួត ទឹកជំនន់) ។

សំណួរសិក្សាជាប់ទាក់ទងនឹងតម្លៃទឹករួមមាន៖

- តើអ្នកបានប្រើប្រាស់ទឹក មកពីប្រព័ន្ធស្រោចស្រពដែរឬទេ?

- បើសិនជាមាន តើជាការបើកបង្ហៀរបញ្ចូល ឬក៏បូមបញ្ចូលស្រែ?

- បើសិនជាការបង្ហៀរបញ្ចូលស្រែ តើទឹកក្នុងស្រែមានជម្រៅប៉ុន្មាន ហើយបានបង្ហៀរបញ្ចូលប៉ុន្មានដងក្នុងអំឡុងពេលរដូវប្រាំង?
- បើសិនត្រូវបូមបញ្ចូលស្រែ តើបានប្រើម៉ាស៊ីនកម្លាំងប៉ុន្មានសេស និងប្រើរយៈពេលបូមប៉ុន្មានម៉ោង?

ចម្លើយតបនឹងសំណួរទាំងនេះ អ្នកស្រាវជ្រាវបានយកទៅគណនា និងវិភាគតាមទៅតាមទំហំផ្ទៃដីស្រោចស្រព និងចំនួនស្រោចស្រពប៉ុន្មានដងក្នុងមួយរដូវ ដើម្បីកំណត់ពីតម្លៃទឹកទាក់ទិននឹងផលិតកម្មស្រូវ ។

តាមការប្រើប្រាស់ទិន្នន័យទាំងនេះ គេអាចធ្វើការប៉ាន់ស្មាននូវទំនាក់ទំនងរវាង បរិមាណទឹកស្រោចស្រពបានប្រើប្រាស់ ធៀបនឹងទិន្នផលស្រូវទាំងនៅរដូវវស្សា និងរដូវប្រាំង ។ ក្នុងការធ្វើវិភាគ ត្រូវយកចិត្តទុកដាក់កំណត់ឲ្យបានច្បាស់នូវ ការចូលរួមចំណែកនៃទឹកនៅក្នុងទិន្នផល (ដោយត្រូវកាត់ចេញនូវ ផលចំណេញបានមកពីទុនផ្សេងទៀត និងពីកត្តាជម្រុញនានា ដូចជា ភាពប៉ិនប្រសព្វ និងជំនាញផ្ទាល់របស់កសិករ ដីស្រែមានជីជាតិល្អ ជាដើម) តាមរយៈការវិភាគប៉ាន់ស្មានអំពី មុខងារផលិតកម្មជាមួយនឹងឥទ្ធិពលថេរនៃដីស្រែ ។ លទ្ធភាពនៃការជ្រើសយកដីស្រែល្អៗ សម្រាប់ការប្រើប្រាស់ទឹកពីប្រព័ន្ធស្រោចស្រព គេបានលើកយកមកពិនិត្យ ហើយរកឃើញថា មិនសូវសំខាន់ទេ ។

## លទ្ធផលស្រាវជ្រាវសំខាន់ៗ

លទ្ធផលស្រាវជ្រាវសំខាន់ៗបានពីការសិក្សានេះ មានជាសង្ខេបដូចខាងក្រោម ។

តួលេខប៉ាន់ស្មាននៃកំណើនទិន្នផល បានមកពីការប្រើប្រាស់ទឹកស្រោចស្រព នៅពេលធ្វើការគណនាតម្លៃទឹកដោយផ្អែកទៅលើទិន្នផលស្រូវ វាមានកម្រិតទាបណាស់ ពោលគឺកំណើននៃការប្រើប្រាស់ទឹក ១% អាចបង្កើនទិន្នផលស្រូវបានប្រមាណ ០,០៦% សម្រាប់ស្រូវវស្សា (ក្រាហ្វិក ១) និង ០,១២% សម្រាប់ស្រូវប្រាំង ។ សម្រាប់ការប្រើប្រាស់ទឹកលើសពី ១.០០០ម៉ែត្រគូបក្នុងស្រែមួយ (ដោយគ្រប់គ្រងទុនឯទៀតឲ្យនៅដដែល) ទំហំទិន្នផលមានកំណើនបន្ថែមតិចតួចណាស់ ។

ក្រាហ្វិក ២ បង្ហាញថា ការបង្កើនថ្លៃទឹកខ្ពស់ពេកមិនមែនជាមធ្យោបាយដ៏ល្អ សម្រាប់បង្កើនប្រាក់ចំណូលទេ ពីព្រោះ កសិករអាចសម្រេចចិត្តមិនប្រើប្រាស់ទឹកវិញជាជាងត្រូវបង់ថ្លៃទឹកកម្រិតខ្ពស់ ។ ដូច្នេះ ថ្លៃទឹកក្នុងមួយម៉ែត្រគូប ដែលលើសពីតម្លៃ ០,០២៥គ.ក ស្រូវ វាធ្វើឲ្យថយចុះដល់ប្រាក់ចំណូលសរុបដែល សកបទ ត្រូវប្រមូលបាន ។

របកគំហើញសំខាន់ៗ រួមមាន៖

- ការតម្លើងថ្លៃទឹក "ខ្ពស់ពេក" មិននាំឲ្យមានកំណើនប្រាក់ចំណូលសម្រាប់ សកបទ ទេ ពីព្រោះកសិករនានាអាចសម្រេចចិត្តមិនប្រើប្រាស់ទឹកស្រោចស្រព ។ ជម្រើសនេះអាចធ្វើឲ្យថយចុះ ដល់ចំនួនប្រាក់សរុបដែលប្រមូលបានពីកសិករ ។

ក្រាហ្វិក ១: កំណើនផលិតភាពនៃទឹកស្រោចស្រព




ក្រាហ្វិក ២: ចំណូលបានពីការបង់ថ្លៃទឹក



**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក
✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
☎ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣, ០១២ ៨៦៧ ២៧៨
🖷 (៨៥៥-២៣) ៨៨០-៧៣៤
អ៊ីមែល៖ cdri@wicam.com.kh
គេហទំព័រ៖ http://www.cdri.org.kh

- កសិករនានា តែងគិតគូរខ្លាំងណាស់អំពីការផ្លាស់ប្តូរថ្លៃទឹកលើសពីតម្លៃដ៏តូចមួយ ។ ដូច្នេះគេអាចប្រើប្រាស់ការតម្លើងថ្លៃទឹក ដើម្បីបែងចែកទឹកឡើងវិញទៅឲ្យការប្រើប្រាស់ផ្សេងទៀត ដែលមិនមែនជាការធ្វើស្រែ ( និងដែលអាចទទួលបានតម្លៃប្រសើរជាង ) ។
- ការបង្កើនផលិតភាពនៃការប្រើប្រាស់ទឹក នៅក្នុងផលិតកម្មស្រូវ នៅពេលមានតម្រូវការទឹកខ្លាំងបំផុត (ឧទាហរណ៍ តម្រូវការទឹកបន្ថែមសម្រាប់ការធ្វើស្រែវស្សា ) ទំនងជាកត្តាដ៏សំខាន់ដើម្បីធ្វើឲ្យមានតុល្យភាពល្អរវាង តម្រូវការប្រើប្រាស់ទឹកផ្សេងៗដែលប្រកួតប្រជែងគ្នា ហើយនិងគោលដៅខាងគោលនយោបាយគ្រប់គ្រងទឹក ។

## លទ្ធផលរកឃើញ សំរាប់ការរៀបចំគោលនយោបាយគ្រប់គ្រងធនធានទឹក

របកគំហើញសំខាន់ៗ សម្រាប់ការរៀបចំគោលនយោបាយគ្រប់គ្រងធនធានទឹក ដែលទទួលបានពីការសិក្សាស្រាវជ្រាវ មានដូចតទៅ៖

- កំណើនផលចំណេញរបស់កសិករ បានមកពីចំណាយលើការស្រោចស្រពក្នុងរដូវវស្សា វាមានកម្រិតទាប ដូច្នេះ កសិករមិនសូវពេញចិត្តបង់ប្រាក់ច្រើនទេ សម្រាប់ទឹកស្រោចស្រពនៅរដូវវស្សា ។
- ការបង្កើនផលិតភាពដំណាំស្រូវក្នុងរដូវវស្សា តាមរយៈការចូលរួមធ្វើការស្រាវជ្រាវ ការអភិវឌ្ឍ ការផ្សព្វផ្សាយបច្ចេកទេស និងការស្វែងរកទីផ្សារ មានសារៈសំខាន់ណាស់ សម្រាប់ការប្រឹងប្រែងគ្រប់គ្រងធនធានទឹក ពិសេសការប្រើប្រាស់ទឹកពីប្រព័ន្ធស្រោចស្រពឲ្យបានកាន់តែប្រសើរ ។ បទពិសោធន៍លើវិស័យនេះនៅប្រទេសជិតខាង អាចមានសារៈសំខាន់ច្រើនដល់ ការជ្រើសរើសគោលនយាបាយឲ្យបានសមស្របសម្រាប់បរិបទប្រទេសកម្ពុជា ។

## ឯកសារយោង

ឯកសារផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រថ្នាក់ជាតិ របស់រាជរដ្ឋាភិបាលកម្ពុជា (ឆ្នាំ២០០៩): ការធ្វើបច្ចុប្បន្នភាពសំរាប់ផែនការប្រចាំឆ្នាំ២០០៩ - ២០១៣ ។